**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រចេះ**

**ក្រុង ក្រចេះ**

**សង្កាត់ ក្រគរ**

**លេខ:** 937/16 សកគ

# ដីកា

# ស្តីពី

# ការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ២០០១
- បានឃើញអនុក្រិត្យលេខ២២ អនក/បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមុខងារ អំណាច តួនាទី និងភារកិច្ច ឲ្យទៅក្រុមប្រឹក្សាឃុំ/សង្កាត់
- យោងលទ្ធផលសិក្ខាសាលាស្តីពី "វិធានការរួមស្តីពីការបង្ការ និងទប់ស្កាត់អំពើហិង្សាលើដៃគូស្និតស្នាលដែលជាប់ពាក់ព័ន្ធនឹងគ្រឿងស្រវឹង" នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦។
- យោងសេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាសង្កាត់ក្រគរស្តីពីវិធានការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹងចុះថ្ងៃទី 11 ខែ វិច្ឆិកា ឆ្នាំ 2016។

ដោយមើលឃើញថាបញ្ហា ដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងស្រវឹងបានធ្វើឲ្យមានអំពើហិង្សា ភាពឥតសណ្តាប់ធ្នាប់ អសន្តិសុខ ភាពក្រីក្រ និងប៉ះពាល់ដល់សុខភាពជារួមរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ក្រគរ ដូច្នេះ ក្រុមប្រឹក្សាសង្កាត់ក្រគរ

# សម្រេច

ប្រការ១៖ ដីកានេះមានគោលបំណងការពារសិទ្ធិស្ត្រី សិទ្ធិកុមារ និងបង្ការអំពើហិង្សាព្រមទាំងលើកកម្ពស់សុខុមាលភាព និងប្រាក់ចំណូលប្រជាពលរដ្ឋក៏ដូចជាការរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងសង្កាត់ក្រគរទាំងមូល។

ប្រការ២៖ ដីកានេះមានវិសាលភាពអនុវត្តទៅលើអ្នកប្រើប្រាស់គ្រឿងស្រវឹងដែលបង្កបញ្ហា ឬ បង្ករការរំខាន ឬបង្កហិង្សានានា ព្រមទាំងការលក់ផលិតផលគ្រឿងស្រវឹងទៅឲ្យអនីតិជនអាយុក្រោម ១៨ឆ្នាំ ឬនៅទីកន្លែងមួយចំនួនក្នុងសង្កាត់ក្រគរដែលបានកំណត់ក្នុងដីកានេះ។

ប្រការ៣៖ ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងដល់ប្រជាពលរដ្ឋ នៅក្នុងសង្កាត់ក្រគរ តាមវិធីផ្សេងៗ ដូចជា ការជួបជុំបងប្អូន មិត្តភក្តិ ជាពិសេសកម្មវិធីប្រជុំ និងវេទិកាផ្សេងៗនៅក្នុងសហគមន៍។

ប្រការ៤៖ ព្រះសង្ឃ ដូនជី អាចារ្យ និងចាស់ព្រឹទ្ធាចារ្យចូលរួមក្នុងបង្កើនការអប់រំដល់អ្នកប្រើប្រាស់គ្រឿងស្រវឹងនៅក្នុង សហគមន៍ និងពិធីបុណ្យផ្សេងៗ។

ប្រការ៥៖ បញ្ចូលកម្មវិធី ការទប់ស្កាត់ អំពើហិង្សាលើដៃគូស្និទ្ធស្នាល ដោយសារគ្រឿងស្រវឹងចូលទៅក្នុង កម្មវិធីវិនិយោគ ឬផែនការអភិវឌ្ឍន៍សង្កាត់ក្រគរ។

ប្រការ៦៖ បញ្ឈប់ការផ្សព្វផ្សាយ និងលក់គ្រឿងស្រវឹងនៅតាមរបង និងក្នុងសាលារៀន វត្តអារ៉ាម និងអាគារសាធារណៈរបស់រដ្ឋ។

ប្រការ៧៖ ហាមផ្សព្វផ្សាយរូបភាព ឬ ធ្វើសកម្មភាពបង្ខិតបង្ខំ ឬ ការជម្រុញលើកទឹកចិត្តក្មេងអាយុក្រោម១៨ឆ្នាំអោយសេពគ្រឿងស្រវឹងនៅក្នុងសហគមន៍។

ប្រការ៨៖ អាជ្ញាធរត្រូវហៅអ្នកប្រព្រឹត្តផ្ទុយពីប្រការ៦ និងប្រការ៧ ដើម្បីធ្វើការអប់រំ និងណែនាំដោយមានកិច្ចសន្យា។ ក្នុងករណី០៣លើក អ្នកប្រព្រឹត្តនៅតែមិនអនុវត្តតាមការណែនាំរបស់អាជ្ញាធរ នឹងត្រូវធ្វើការផាកពិន័យនៅលើកទី០៤ ជាប្រាក់ចាប់ពី១០.០០០រៀល ទៅ៥០.០០០រៀល និងលើកទី៥ ចាប់ពី ១០០.០០០រៀល ទៅ១៥០.០០០រៀល។ តែក្នុងករណីនៅមិនរាងចាលទៀត លើកទី៦ ចាប់ពី ២៥០.០០០រៀល ទៅ៥០០.០០០រៀល ឬត្រូវចាត់វិធានការតាមច្បាប់ជាធរមាន។

ប្រការ៩៖ ដីកានេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅសង្កាត់ក្រគរ, ថ្ងៃទី.....11.....ខែ.....វិច្ឆិកា.....ឆ្នាំ២០១៦

**ចៅសង្កាត់ក្រគរ**

អ៊ឹម_ឆាយ៉ា

<u>ចម្លងជូន</u>

- សាលាក្រុងក្រចេះ (ដើម្បីជូនជ្រាប)
- ក្រុមប្រឹក្សាសង្កាត់, ប៉ុស្តិ៍នគរបាល, មេភូមិ និងក្រុមបណ្តាញទាំងអស់ (ដើម្បីអនុវត្ត)
- ឯកសារកាលប្បវត្តិ